# ផ្នែកទី 2

# ផែនការ និង គម្រោង

# ជំពូក 10 គំនិតមូលដ្ឋាន និង គោលបំណង

## 10.1 គំនិតមូលដ្ឋាន

### 10.1.1 ការអភិវឌ្ឍន៍គំរូ

ការសិក្សាលើការស្តារ និង ជួសជុលឡើងវិញនូវប្រព័ន្ធផលិតកម្មកសិកម្មក្នុងតំបន់អាងទឹកស្លាគូនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើឡើងសំរាប់ការជ្រើសរើសនូវផ្ទៃដីស្រោចស្រព (650គម$^2$ នៃផ្ទៃដីសរុប) ដែលមានក្នុងអាងទឹកស្ទឹងស្លាគូ ។

ចាប់តាំងពីការសិក្សាបានចាប់ផ្តើម ក្រុមសិក្សាបានវិភាគស្ថានភាពបច្ចុប្បន្ន បញ្ហា និង ករិតកំណត់របស់តំបន់សិក្សា ហើយរៀបចំផែនការមេសំរាប់ផែនការស្តារ និង ជួសជុលឡើងវិញនូវប្រព័ន្ធផលិតកម្មកសិកម្មដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា ។ លក្ខណៈនៃប្រព័ន្ធផលិតកម្មកសិកម្មក្នុងតំបន់សិក្សាមានៈ i) ការធ្វើស្រែតែ1ដងក្នុងមួយឆ្នាំដោយពឹងផ្អែកលើស្ថានភាពទឹកភ្លៀង និង ii) ការបង្កើតប្រព័ន្ធដំណាំចំរុះខ្នាតតូចដែលមានដំណាំសំរាប់លក់ បសុសត្វ ។ល ។

ដូចដែលបានដឹងហើយថា ប្រព័ន្ធផលិតកម្មកសិកម្ម ដែលបានស្នើឡើងក្នុងផែនការមេមានបីប្រភេទ គឺ ផែនការជួសជុលឡើងវិញប្រព័ន្ធស្រោចស្រពផ្នែកខាងលើស្ទឹងស្លាគូ (USP) ផែនការស្តារឡើងវិញអាងទឹកតូចៗ និង ផែនការអភិវឌ្ឍន៍ស្រះទឹកតូចៗ (PDP) ។

USP ត្រូវបានចាត់ទុកជា "ការអភិវឌ្ឍន៍ផ្ទៃធនធានទឹកសំរាប់ផ្ទៃដីធំ" និង SRP PDP ត្រូវបានចាត់ទុកជា "ការអភិវឌ្ឍន៍ធនធានទឹកខ្នាតតូចសំរាប់ការធ្វើដំណាំស្រូវ និង ដំណាំបន្ទាប់បន្សំ" និង "ការអភិវឌ្ឍន៍ប្រព័ន្ធទ្រង់ទ្រាយការដាំដុះចំរុះខ្នាតតូច" ក្នុងភូមិ ឬ តាមគ្រួសារ ។

ដូច្នេះប្រព័ន្ធផលិតកម្មទាំងបីបានដាក់បញ្ចូលជា "ផែនការគំរូសំរាប់ការស្តារ និង ជួសជុលឡើងវិញនូវប្រព័ន្ធផលិតកម្មកសិកម្មក្នុងប្រទេសកម្ពុជា" ។

**តារាងផែនការគំរូ**

| គំរូ | ផែនការក្នុងការសិក្សា | ដំណាំគោលដៅ និង សត្វ |
|---|---|---|
| ការអភិវឌ្ឍន៍ផ្ទៃធនធាន ទឹកសំរាប់ផ្ទៃដីស្រោចស្រពធំ | ផែនការជួសជុលឡើងវិញប្រព័ន្ធស្រោចស្រពផ្នែកខាងលើស្ទឹងស្លាគូ (USP) | ស្រូវ និង ដំណាំបន្ទាប់បន្សំ |
| ផែនការស្តារឡើងវិញនូវអាងទឹកតូច | ផែនការស្តារឡើងវិញអាងទឹកតូច (SRP) | ស្រូវ និង ដំណាំបន្ទាប់បន្សំ |
| ផែនការអភិវឌ្ឍន៍ស្រះទឹកតូច | ផែនការអភិវឌ្ឍន៍ស្រះទឹកតូច (PDP) | សំណាប បន្លែ ដំណាំសំរាប់លក់ បសុសត្វ ។ល ។ |

ផ្ទៃដីកសិកម្មបានបញ្ជាក់ដោយគំរូមួយ ឬ គំរូពីរ បី ដូចបានបង្ហាញក្នុងរូបភាពខាងក្រោមៈ




រូបភាព ទំហំរបស់ផែនការគំរូ និង ប្រព័ន្ធផលិតកម្មកសិកម្ម

នៅក្នុងការសិក្សានេះ USP SRP PDP ត្រូវបានរៀបចំជា "គំរោងឯករាជ្យ" ប៉ុន្តែ SRP និង PDP អាចនឹងត្រូវស្នើបន្ថែមការស្រោចស្រពផ្ទៃដីធំៗ សំរាប់ការកំណត់គោលបំណង និង ទ្រទ្រង់ប្រព័ន្ធដាំដុះចំរុះរបស់គ្រួសារកសិករ ។

## 10.1.2 ដំណាក់កាលអភិវឌ្ឍន៍

កំរិតកំណត់នៃការអភិវឌ្ឍន៍មានឥទ្ធិពលយ៉ាងខ្លាំងទៅលើតំលៃគំរោង និង ការទ្រទ្រង់ ។ ការងារអភិឌ្ឍន៍ គួរតែធ្វើតាមដំណាក់កាលអាស្រ័យលើស្ថានភាពបច្ចុប្បន្នរបស់ផ្ទៃដីដាំដុះដែលបានកំណត់ ។

លទ្ធផលនៃការសិក្សាបង្ហាញថា នៅទីនោះនៅមានការខ្វះខាតស្បៀង ជំងឺឆ្លង (មូលហេតុនៃការស្លាប់ដោយជំងឺធំបំផុតនៅខេត្តតាកែវ គឺជំងឺគ្រុនចាញ់ បន្ទាប់មករោគរបេង និង បណ្តាលមកពីជំងឺរលាកទងសួត) ការខ្វះខាត ការប្រើប្រាស់ទឹកដែលមានសុវត្ថិភាព និង ឧបករណ៍អនាម័យ ។ ចំនួននៃកម្មវិធី និង គំរោងសំរាប់កែលំអស្ថានភាពទាំងអស់នេះត្រូវបានធ្វើដោយ IOs និង NGOs ក្នុងខេត្តតាកែវ ហើយផលប្រយោជន៍ ពិតប្រាកដត្រូវបានបង្កើតឡើងតាមរយៈគំរោង និង កម្មវិធីទាំងអស់នោះ ។ NGOsមូលដ្ឋានដែលបុគ្គលិករបស់គេបានបណ្តុះបណ្តាលដោយគំរោងដែលបានចាប់ផ្តើមកម្មវិធីរបស់ពួកគេ ដោយសហប្រតិបត្តិការជាមួយ NGOs និង IOs អន្តរជាតិ ។

កម្មវិធីសីលាត្រូវបានធ្វើជាមួយការសំរបសំរួលនៃ UNDP និង ក្រសួងអភិវឌ្ឍន៍ជនបទ (MRD) ដែលបានប្រតិបត្តិនៅក្នុងខេត្តជាច្រើនរួមទាំងខេត្តតាកែវផងដែរ ។ កម្មវិធីគឺឆ្ពោះទៅរកការកែលំអហេដ្ឋា

រចនាសម្ព័ន្ធជនបទដូចជា: ផ្លូវថ្នល់ សំណង់ សាលារៀន អណ្តូងទឹក ស្រះទឹកជាលក្ខណៈសហគមន៍សំរាប់ប្រើប្រាស់តាមគ្រួសារ ។ល។ ដែលម្ចាស់ការទ្រទ្រង់ដោយគណៈកម្មការភូមិអភិវឌ្ឍន៍ភូមិ (VDC) ។ ក្នុងការពិចារណាលើស្ថានភាពទាំងនោះ គឺរិតគោលដៅនៃការអភិវឌ្ឍន៍របស់ផែនការ ដែលនឹងរៀបចំជា "ការកែលំអផលិតកម្មកសិកម្មដោយ ការអភិវឌ្ឍន៍ធនធានទឹក និង កែលំអសំណង់ស្រោចស្រព" ។ មិនចាំបាច់និយាយពីគោលដៅអភិវឌ្ឍន៍ផ្សេងទៀត ដែលគួរតែត្រូវពិចារណានៅក្នុងផែនការឡើយ ។

តារាងខាងក្រោមបង្ហាញពីដំណាក់កាលអភិវឌ្ឍន៍ សេចក្តីត្រូវការ បញ្ហា និង គំរោងដែលរៀបផែនការជាដំណាក់កាល ។

## តារាងដំណាក់កាលអភិវឌ្ឍន៍ និង គោលដៅ

| គោលដៅរបស់ដំណាក់កាលអភិវឌ្ឍន៍ និង តំរូវការ | បញ្ហាជាចំបង | សមាសភាគគំរោង |
|---|---|---|
| កំរិត-1:<br>តំរូវការចាំបាច់របស់មនុស្ស<br>• ការថែរក្សាសុខភាពជាបឋម<br>• ទឹកផឹក<br>• លំនៅដ្ឋាន<br>• បណ្តុះបណ្តាលវិជ្ជាជីវៈ ។ល។ | ភាពក្រីក្រ និង ការខ្វះខាតស្បៀង<br>• អាហារ<br>• ខ្វះខាតទឹកផឹក<br>• កំលាំងពលកម្មស្ត្រី និង កុមារ<br>• លំនៅដ្ឋាន<br>• ការងារបន្តិចបន្តួច<br>• ជម្ងឺឆ្លង ។ល។ | • សុខភាព ( ការចាក់ថ្នាំបង្ការ ផែនការគ្រួសារ)<br>• ការសិក្សាបឋម<br>• ជំនួយស្បៀងសង្គ្រោះបន្ទាន់ ( ស្បៀងពលកម្ម) ។ល។ |
| កំរិត-2:<br>ហេដ្ឋារចនាសម្ព័ន្ធ<br>• ការកែលំអប្រព័ន្ធស្រោចស្រព<br>• ផ្លូវកសិដ្ឋាន<br>• ការផ្សព្វផ្សាយកសិកម្ម | ផលិតកម្មទាប<br>• ខ្វះខាតទឹក<br>• ចំណូលទាប<br>• ខ្វះបច្ចេកទេសកសិកម្ម ។ល។ | • ការស្តារឡើងវិញឧបករណ៍ស្រោចស្រព<br>• ការអភិវឌ្ឍន៍ធនធានទឹក<br>• ការគ្រប់គ្រងសត្វចង្រៃ<br>• ការបណ្តុះបណ្តាលកសិករ ។ល។ |
| កំរិត-3:<br>ការកាត់បន្ថយតំលៃផលិតកម្ម<br>• កែលំអកំរៃនៅក្នុងសកម្មភាពផលិតកម្ម | ប្រសិទ្ធិភាពទាប (ចំណូល)<br>• តំលៃពលកម្មខ្ពស់<br>• តំលៃទុនខ្ពស់<br>• ការបាត់បង់ក្នុងពេលច្រូតកាត់<br>• ឥទ្ធិពលនៃការទិញ លក់ទាប<br>• ការបាត់បង់ដោយការកែច្នៃក្រោយពេលច្រូតកាត់ | • ក្រុមកសិករសំរាប់ការទទួល និង ការផ្សព្វផ្សាយ<br>• ក្រោយការច្រូតកាត់ ទីផ្សារ<br>• សហគមន៍កសិករប្រើប្រាស់ទឹក (FWUC) ។ល។ |
| កំរិត-4:<br>កសិ-ឧស្សាហកម្ម<br>• ការពិនិត្យគុណភាព<br>• ការបង្កើតតំបន់ផលិតកម្ម<br>• តំលៃបន្ថែមលើការកែច្នៃ ។ល។ | តំលៃបន្ថែមទាប<br>• ខ្វះជំនាញកែច្នៃ<br>• ខ្វះថវិកា<br>• ខ្វះទីផ្សារ ។ល។ | • បណ្តុះបណ្តាលជំនាញកែច្នៃ<br>• ការចាប់ផ្តើមនៃផ្នែកឯកជន<br>• ឥណទានខ្នាតតូចសំរាប់ កសិ-ឧស្សាហកម្ម |

តំបន់សិក្សាត្រូវបានចាត់ទុកស្ថិតនៅកំរិត-1 ឬកំរិត-2 និង ការអភិវឌ្ឍន៍ដ៏ទូលំទូលាយនៃហេដ្ឋារចនាសម្ព័ន្ធសំរាប់ផលិតកម្មកសិកម្មគឺជាប្រការចាំបាច់ ។

### 10.1.3 កំរិតកំណត់របស់ប្រព័ន្ធស្រោចស្រព

ចំពោះប្រព័ន្ធស្រោចស្រពមានបីប្រភេទដូចខាងក្រោម:

**(1) បច្ចេកទេសស្រោចស្រព**

បច្ចេកទេសប្រព័ន្ធស្រោចស្រពសំរាប់ត្រួតពិនិត្យ គ្រប់គ្រងសំណង់រហូតដល់ប្រព័ន្ធចែកចាយទឹក ។ ទឹកស្រោចស្រពបានបែងចែកទៅតាមស្រែនីមួយៗតាមទ្វារនៃសំណង់ នៅប្រឡាយចែកចាយបច្ចេកទេសប្រព័ន្ធស្រោចស្រពអាចគ្រប់គ្រងទឹកតាមនាទីដោយប្រដាប់វាស់ស្ទង់រហូតដល់ដីកសិដ្ឋាន ដែលនៅខាងចុងប្រព័ន្ធ ។

**(2) ការស្រោចស្រពពាក់កណ្តាលបច្ចេកទេស**

ប្រព័ន្ធស្រោចស្រពពាក់កណ្តាលបច្ចេកទេសសំរាប់ត្រួតពិនិត្យ គ្រប់គ្រងសំណង់នៅលើប្រឡាយមេ និងប្រឡាយបន្ទាប់បន្សំ ។ ការស្រោចស្រព គឺការចែកចាយទឹកទៅកាន់ប្លុកចែកចាយតាមទ្វារនៃសំណង់ ។ ចាប់ពីប្រឡាយចែកចាយទឹក ត្រូវបានចែកចាយដោយគ្មានសំណង់អចិន្ត្រៃយ៍ ប៉ុន្តែការត្រួតពិនិត្យជាបណ្តោះអាសន្នជាមួយសំភារៈមូលដ្ឋានដូចជាដី ឈើ ។ល។

**(3) ការស្រោចស្រពគ្មានលក្ខណៈបច្ចេកទេស**

ប្រព័ន្ធស្រោចស្រពគ្មានលក្ខណៈបច្ចេកទេសសំរាប់ត្រួតពិនិត្យសំណង់មួយចំនួននៅលើប្រឡាយមេ និងប្រឡាយបន្ទាប់បន្សំ ។ សំណង់ទាំងនោះប្រើប្រាស់សំរាប់ត្រួតពិនិត្យកំពស់ទឹកនៅក្នុងប្រឡាយដែលចែកចាយទឹកទៅប្រឡាយផ្សេងៗទៀត ។ របៀបចែកចាយដូចជាការផ្លាស់ប្តូរពីមួយទៅមួយធ្វើអោយទឹកមិនគ្រប់គ្រាន់ដល់ប្រព័ន្ធស្រោចស្រព ។ តាមការពិចារណាអំពីកំរិតសំណង់ស្រោចស្រព និង បទពិសោធនៃការគ្រប់គ្រងទឹកដោយសមាគមន៍កសិករប្រើប្រាស់ទឹក (FWUC) និង មន្ទីរធនធានទឹក និង ឧតុនិយម (DWRAM) បច្ចុប្បន្ននេះ ប្រព័ន្ធស្រោចស្រពពាក់កណ្តាលបច្ចេកទេសត្រូវបានចាត់ ទុកជាគោលដៅកំរិតអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន ។ គោលដៅកំរិតរបស់សំណង់នីមួយៗបានរៀបរាប់លំអិតក្នុងផ្នែក 13.2 "គោលដៅកំរិតនៃការស្តាបនាឡើងវិញ និង ការស្តារ" ។

## 10.2 គោលបំណង

### 10.2.1 គោលបំណងនៃការចូលរួម

អាចនិយាយបានថាការចូលរួមរបស់អ្នកទទួលផលប្រយោជន៍ ជានិច្ចជាកាលមិនបានគាំទ្រដល់កិច្ចសន្យាក្នុងការអភិវឌ្ឍន៍ឡើយ ប៉ុន្តែការគាំទ្រមិនអាចសំរេចបាន ដោយគ្មានការចូលរួមឡើយ ។

ការសាងសង់សំណង់ស្រោចស្រពមួយចំណែក ត្រូវរ៉ាប់រងដោយអ្នកទទួលផលប្រយោជន៍ដោយខ្លួនឯង ។ ម៉្យាងវិញទៀតការងារប្រតិបត្តិការ និង ការថែទាំ (O&M) សំណង់ស្រោចស្រព ក៏នឹងត្រូវធ្វើដោយអ្នកទទួលផលប្រយោជន៍ ឬ សមាគមន៍កសិករប្រើប្រាស់ទឹក (FWUC)/ ក្រុមកសិករប្រើប្រាស់ទឹក (FWUG) ។

សំរាប់ការងារទាំងអស់នេះអ្នកទទួលផលប្រយោជន៍ គួរតែចូលរួមពីដំណាក់កាល ដំបូងរបស់គំរោង ដូចជា ផែនការ និង ការគ្រោង ។

សំរាប់គំរោងស្តារអាងទឹកតូចៗ បញ្ហារួមគឺ "ការធ្វើស្រែក្នុងអាងទឹកខុសច្បាប់" ។ ជាទូទៅអ្នកធ្វើស្រែខុសច្បាប់ក្នុងអាងទឹក និង អ្នកធ្វើស្រែក្នុងផ្ទៃដីស្រោចស្រពដែលជាដីរបស់ភូមិ ហើយបញ្ហា និង ការវិវាទទាំងនោះត្រូវបានដោះស្រាយដោយអ្នកទទួលផលប្រយោជន៍ខ្លួនឯង ដោយមានការសំរបសំរួលពីក្រសួងធនធានទឹក និង ឧតុនិយម (MOWRAM) និង ការិយាល័យគំរោង ។

## 10.2.2 ភាពដែលអាចប្រព្រឹត្តទៅបាន និង ភាពដែលអាចទុកចិត្តបាន

ចាប់តាំងពីគំរោងស្រោចស្រពជាចំបងអាស្រ័យដោយទឹកភ្លៀង វាគឺជាប្រការសំខាន់ណាស់ក្នុងការសន្មត់លើភាពដែលអាចប្រព្រឹត្តទៅបាន និង ភាពដែលអាចទុកចិត្តបានក្នុងផែនការសំរាប់គំរោងស្រោចស្រព ។ 80% នៃភាពដែលអាចទុកចិត្តបាន គឺជាទូទៅត្រូវបានអនុវត្ត " 80%" មានន័យថាតំបន់ស្រោចស្រពដែលបានស្នើអាចទទួលបរិមាណទឹកដែលស្នើក្នុង 4 នៃ 5 ឆ្នាំ ។ កំរិតភាពដែលអាចប្រព្រឹត្តទៅបានគឺកំណត់កំរិតនៃការអភិវឌ្ឍន៍គំរោង ដូច្នេះនោះជាផ្លូវសេដ្ឋកិច្ចដ៏ពិតប្រាកដមួយដែលអាចជឿទុកចិត្តបាន ។

ក្នុងប្រទេសកម្ពុជាជារឿយៗតួរលេខផ្ទៃដីស្រោចស្រព ត្រូវបានប៉ាន់ស្មានដោយឈរលើមូលដ្ឋាន " តំលៃមធ្យម " និង " កំរិតប្រចាំឆ្នាំ " ។ តំលៃមធ្យមសំរាប់រយៈពេលវែងជាញឹកញាប់មិនបង្ហាញអោយឃើញនូវការខ្វះខាតទឹកជាក់លាក់សំរាប់ដំណាំ និង ទឹកជំនន់ដ៏ធ្ងន់ធ្ងរឡើយ ។ សូម្បីនៅរដូវភ្លៀង ក៏មានភាពរាំងស្ងួតមួយរយៈដែរ ដែលនាំអោយប៉ះពាល់ដល់ការលូតលាស់របស់ដំណាំ ហើយស្ថានភាពបែបនេះត្រូវដាក់បញ្ចូលក្នុងការពិចារណាដោយការវិភាគភាពដែលអាចប្រព្រឹត្តទៅបាន ។

## 10.2.3 ការថែទាំ និង ការកែលំអមុខងារដើម

មុនពេលផែនការ មុខងារដើមនៃប្រព័ន្ធដែលមានស្រាប់ គួរត្រូវបានធ្វើការត្រួតពិនិត្យ ។ ប្រសិនបើមុខងារដើមសមល្មមសំរាប់អនុវត្តន៍ផ្ទៃដីស្រោចស្រព ការងារស្តារឡើងវិញ គួរគប្បីស្នើឡើងទោះណាវាមិនសមល្មម ការជួសជុលឡើងវិញគប្បីស្នើឡើង ។ ទោះបីជាយ៉ាងណាក៏ដោយការជួសជុលឡើងវិញមិនមានន័យជានិច្ចថាការពង្រីកផ្ទៃដីស្រោចស្រពជាមួយការអភិវឌ្ឍន៍នៃអាងទឹកធំៗ និង ប្រឡាយឡើយ ។ ការពិចារណាលើភាពត្រឹមត្រូវនៃបច្ចេកទេស និង ការប៉ះពាល់បរិស្ថាន វាបានបញ្ជាក់ពីការថែទាំសមត្ថភាពដើម និង ពង្រីកផ្ទៃដីស្រោចស្រព ឬ វិធីសាស្ត្រស្រោចស្រពគួរតែបានកំណត់អោយបានសមស្រប ។

# ជំពូក 11 ធនធានទឹក

ធនធានទឹក គឺជាបញ្ហាសំខាន់បំផុតមួយ សំរាប់ផែនការ និង ការគ្រោងរបស់ប្រពន្ធ័ស្រោចស្រព ។ ជំពូកនេះទាក់ទងជាមួយវិធីសាស្ត្រទាំងឡាយសំរាប់ប៉ាន់ស្មានភាពអាចរកបានរបស់ធនធានទឹក និង ទឹកជំនន់ ជាពិសេសសំរាប់ដីទំនាបដែលលាតសន្ធឹងទៅផ្នែកខាងកើតរបស់ភ្នំដងរែកនៅក្នុងប្រទេសកម្ពុជា ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារការខ្វះខាតទិន្នន័យ និង ពត៌មាន ឯកសារនេះគឺជាកម្មវត្ថុសំរាប់ការពង្រឹងដោយមានទិន្នន័យ និង ពត៌មានបន្ថែមថ្មីៗ ។

## 11.1 ភាពអាចរកបាននៃទឹក

ភាពអាចរកបាននៃទឹក គឺជាពត៌មានសំខាន់ណាស់សំរាប់ការគ្រោងរបស់សំណង់ទន្លេ ។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានទិន្នន័យរំហូរដែលអាចរកបានភាគច្រើនរបស់ទន្លេតូចៗ និង ស្ទឹងនៅក្នុងប្រទេសកម្ពុជា ។

ទំនាក់ទំនងរវាងរំហូរប្រចាំឆ្នាំ (AQ) និង ទឹកភ្លៀងប្រចាំឆ្នាំ (AR) និងបង្ហាញដោយសមីការ[1] ខាងក្រោម ។

$$AQ(mm) = 0.982AR - 863$$

យោងលើសមីការនេះ រំហូរប្រចាំឆ្នាំនៅដីទំនាប ដែលលាតសន្ធឹងពីខេត្តបាត់ដំបងដល់ខេត្តតាកែវ គឺ 315មម ដែលនៅកន្លែងទឹកភ្លៀងប្រចាំឆ្នាំគឺប្រហែល 1.200មម ។ អត្រារំហូរប្រចាំឆ្នាំគឺ 25% ។ បើទឹកភ្លៀង ប្រចាំឆ្នាំស្មើនឹង 1500មម រំហូរប្រចាំឆ្នាំគឺ 610មម ដែលនោះប្រហែលពីរដងនឹងរំហូរប្រចាំឆ្នាំក្នុងទឹកភ្លៀងប្រចាំឆ្នាំ 1200មម ។ នៅពេលដែលទឹកភ្លៀងតិចជាង 1200មម សមីការខាងលើមិនអាចអនុវត្តបានទេ ។ ការបាត់បង់ និង ការធ្លាក់ចុះរបស់រំហូរទាំងពីរនេះដូចទឹកភ្លៀងថយចុះ ។ រំហូរប្រចាំឆ្នាំដែលបានគ្រោងទុក មុខជាប្រហែល 200មម នៃ 1000មម ទឹកភ្លៀងប្រចាំឆ្នាំ ឬ 150មម នៃ 900មម ទឹកភ្លៀងប្រចាំឆ្នាំ ។

ដើម្បីប៉ាន់ស្មានរំហូរប្រចាំខែរបស់រំហូរទន្លេពីភ្នំដងរែកទៅកាន់ដីទំនាបខាងកើត សមីការ[2] ជាបន្តបន្ទាប់នឹងមានប្រយោជន៍ ។

$$ER = R - L$$

$$L = 1.23 \times ET_0 \times (1 - \exp^{-0.006 \times R})$$

ដែល ER: ទឹកភ្លៀងបានការដែលចូលរួមទៅរំហូរ (មម)

R: ទឹកភ្លៀងប្រចាំខែ (មម)

L: ការបាត់បង់ (មម)

ETo: បួតង់ស្យែលអេវ៉ាប៉ូត្រែនស្ពៃរ៉េសិន (មម)

---

[1] តារាងភ្ជាប់ A: ជលសាស្ត្រ ការសិក្សានូវការស្តារប្រព័ន្ធស្រោចស្រពនៅក្នុងប្រទេសកម្ពុជា លេខាធិការដ្ឋានទន្លេមេគង្គ មិថុនា ឆ្នាំ 1994 ។

[2] សមីការនេះបានទទួលពីសហសម្ព័ន្ធវិភាគរវាងទឹកភ្លៀងប្រចាំខែ និង រំហូរប្រចាំខែរបស់អាងស្ទឹងព្រែកត្នោត ។

$$Q = 0.66ER_0 + 0.23ER_1 + 0.08ER_2 0.015ER_3 + 0.01ER_4 + 0.005ER_5$$

ដែល Q: រំហូរប្រចាំខែ (មម)

ER: ទឹកភ្លៀងបានការ (មម)

តួរលេខដែលភ្ជាប់មានរៀងលំដាប់លំដោយ 0 1 2 3 និង 4 បង្ហាញខែនេះ ខែមុន 2 ខែកន្លងទៅ បីខែ និង បួនខែកន្លងទៅ ។

**តារាង ប៉ាន់ស្មាន ETo ពីទិន្នន័យអាកាសធាតុដែលទទួលបានពីពោធិ៍នតុងដោយការកែប្រែ តែនមែន (Modified Penman)**

| មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|
| 162 | 174 | 216 | 206 | 191 | 167 | 153 | 159 | 140 | 133 | 150 | 156 |

ប្រហែល 65% នៃទឹកភ្លៀងបានការ ដែលចូលរួមទៅរំហូរក្នុងខែដូចគ្នា 25% នៅខែទីពីរ និង 8% ទៅខែទីបី ។

ក្នុងករណីស្ទឹងតូចៗ ឧទាហរណ៍ បើអ្នកទទួលពត៌មានថាស្ទឹងមិនហូរនៅក្នុងរដូវប្រាំង ពីខែកុម្ភៈ ដល់ ឧសភា មេគុណរបស់ $ER_3$ $ER_4$ និង $ER_5$ ត្រូវថយចុះ ឬ សូន្យ និង ជួសវិញ មេគុណរបស់ $ER_0$ និង $ER_1$ ដែលផ្តល់ឱ្យតំលៃធំ ដើម្បីអោយរំហូរប្រចាំខែក្នុងកំឡុងពី ខែកុម្ភៈ ដល់ ខែឧសភាក្លាយជាសូន្យ ឬ តិចបំផុត ។

រំហូរប្រចាំខែរបស់ស្ទឹងតូចៗ ដែលមានប្រភពដើមពីតំបន់ភ្នំនៅក្នុងតំបន់ ជាកន្លែងដែលទឹកភ្លៀងប្រចាំឆ្នាំគឺប្រហែល 1200មម មានបង្ហាញខាងក្រោម ។

**តារាង រំហូរនៅក្នុងស្ទឹងតូចនៅក្នុងដីធំនាប**

x1.000 ម ³/ខែ/គម²

| រយះពេលខួប | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 2 ឆ្នាំ | គ្មាន | 0 | 0 | 0 | 0 | 7 | 9 | 19 | 59 | 85 | 35 | 9 |
| 5ឆ្នាំ | គ្មាន | 0 | 0 | 0 | 0 | 0 | 4 | 6 | 39 | 33 | 21 | 5 |

ស្ទឹងតូចៗរីងស្ងួតពីខែ មករា និង ខែ ឧសភា លើកលែងតែមានភ្លៀងធ្លាក់ខ្លាំងពីរ បីដង ។ រំហូរចាប់ផ្តើមនៅក្នុងខែ មិថុនា ឬ កក្កដា ។ ខែ កញ្ញា និង ខែ តុលា គឺជារដូវដែលមានរំហូរខ្ពស់បំផុត ។ ក្នុងខែ វិច្ឆិកា និង ខែ ធ្នូ រំហូរបានថយចុះគួរឱ្យកត់សំគាល់ ។

បើផ្ទៃរងទឹកភ្លៀងរបស់ស្ទឹងតូច គឺភាគច្រើនជាស្រូវពឹងលើទឹកភ្លៀង រំហូរនឹងមិនត្រូវបានសង្ឃឹមទុករហូតដល់ដីស្រែពេញដោយទឹក និង ជាពេលចាប់ផ្តើមរបស់រំហូរ ដែលជាញឹកញាប់នាខែ កក្កដា ក្នុងឆ្នាំធម្មតា និង ប្រហែលជាខែ សីហា ឬ កញ្ញា ក្នុងឆ្នាំរាំងស្ងួត ។

គួរកត់សំគាល់ថា រំហូររបស់ស្ទឹងមិនអាចបង្វែរទឹកទាំងអស់ ដោយសំណង់បង្វែរទឹកតូចទេ ដែលគ្មានសមត្ថភាពស្តុកទឹក ពីព្រោះចំណែកធំរបស់រំហូរ គឺរំហូរព្យុះ ដែលជាទូទៅគឺធំជាងសមត្ថភាពបង្វែរទឹកនៃសំណង់បញ្ចូលទឹក ។ វិមាណប្រចាំខែដែលបង្វែរដោយសំណង់បញ្ចូលទឹកមួយដែលប៉ាន់ស្មានត្រួសៗដោយលក្ខខ័ណ្ឌ[3] ជាបន្តបន្ទាប់ ។

---

[3] លក្ខខ័ណ្ឌបានសំរេចដោយប្រៀបធៀបជាមួយធារទឹកទន្លេរៀងរាល់ម៉ោង ដែលវាស់ដោយប្រដាប់វាស់ស្ទង់កំពស់ទឹកស្វ័យប្រវត្តិដែលបាន តំលើងនៅការដ្ឋានអាងទឹកទំនប់លោក លើស្ទឹងស្លាគូ និង ការគ្រោងសមត្ថភាពបង្វែរទឹក។ រយៈពេលវាស់វែងគឺនៅតែត្រូវបានកំណត់ក្នុងរយៈពេលពីរបីខែ ។ ដូច្នោះលក្ខខ័ណ្ឌគឺសំដៅលើការពិនិត្យឡើងវិញ នៅពេលដែលទិន្នន័យធារទឹកត្រូវបានប្រមូលសំរាប់រយៈពេលពីរបីឆ្នាំ ។

Qr > Qc/0.7, Qin = Qc

Qr < Qc/0.7, Qin = 0.7 Qr

លើលក្ខខ័ណ្ឌដែល Qc = CA/(50～150)

ដែល Qin: បរិមាណទឹកដែលបង្វែរប្រចាំខែ

Qr: ធារទឹកប្រចាំខែ

Qc: មាឌទឹកចូល (ម³ / វិ)

CA: ផ្ទៃរងទឹកភ្លៀង (គម²)

## 11.2 ទឹកជំនន់

ធារទឹកជំនន់ជាពតិមានសំខាន់ណាស់សំរាប់ការគ្រោងសំណង់របស់ទន្លេ និង ប្រឡាយទឹក ។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានទិន្នន័យទឹកជំនន់ដែលអាចរកបានសំរាប់ស្ទឹងតូចៗ និង ខ្សែទឹកនៅក្នុងប្រទេសកម្ពុជាទេ ។

វិធីសាស្ត្របួនយ៉ាងដូចជា : (1) វិធីសាស្ត្រ (ដែលក្នុងនេះហៅថាវិធីសាស្ត្រ IRS) បានត្រូវយល់ព្រមក្នុងការសិក្សានូវការស្តារឡើងវិញប្រព័ន្ធស្រោចស្រពនៅក្នុងប្រទេសកម្ពុជា ឆ្នាំ 1994 របស់លេខាធិការដ្ឋានទន្លេមេគង្គ អាស្រ័យលើកត្តារីកចំរើន សំរាប់ភាពកើតឡើងជាញឹកញាប់នៃទឹកជំនន់ក្នុងផ្ទៃរងទឹកភ្លៀងក្នុងប្រទេសថៃ ដែលមានផ្ទៃតិចជាង 15.000គម² និង ការីតកំពស់ក្រោម 100ម និង (2) រូបមន្ត Rational (3) វិធីសាស្ត្រឯកត្តាក្រាហ្វិកជលសាស្ត្រ (Unit Hydrograph Method) (4) រូបមន្តប Manning ត្រូវបានពន្យល់ ។

### (1) ភ្លៀងដែលអាចកើតមាន

រូបមន្ត Rational និង វិធីសាស្ត្រឯកត្តាក្រាហ្វិកជលសាស្ត្រត្រូវការភ្លៀងដែលអាចកើតមាន ។ វិធីសាស្ត្រតូម៉ាស់ និង វិធីសាស្ត្រហាហ្សែន បានបង្ហាញនូវវិធីសាស្ត្រងាយៗ ដើម្បីប៉ាន់ស្មានតំលៃដែលអាចកើតមានដោយការបែងចែកស្ថិតិជាលំដាប់ (Plotting Order Statistics) លើក្រដាសប្រូបាប៊ីលីតេ (Probability Paper ) យោងទៅលើទីតាំងនៃការបែងចែក ។

វិធីសាស្ត្រ ហាហ្សែន : $P = 100(2m-1)/(2N)$

វិធីសាស្ត្រ តូម៉ាស់ : $P = 100m/(N+1)$

ដែល N: ចំនួននៃកំណត់ត្រា

m: លំដាប់ចំនួននៃតំលៃចុះ ដោយធំបំផុតស្មើនឹង 1

P: ទីតាំងនៃការបែងចែក

ក្រដាសខាងក្រោម គឺជាសំណាករបស់ក្រដាសប្រូបាប៊ីលីតេ ។ ក្រដាសមេលេខជំរឿនការចែកចាយធម្មតានេះជាញឹកញាប់ត្រូវបានប្រើប្រាស់សំរាប់ប៉ាន់ស្មានប្រូបាប៊ីលីតេ របស់ទឹកភ្លៀងលើសប្រចាំថ្ងៃ ។




រូបភាព ក្រដាសសំរាប់ការវិភាគការចែកចាយ ឡុកន័រម៉ាល់

**(Paper of Log-normal Distribution Analysis)**

### (2) វិធីសាស្ត្រ IRS

វិធីសាស្ត្រនេះគណនាដោយសមីការជាបន្តបន្ទាប់ ។

$MAF = AREA^{0.9}$

$Q_{10} = 1.53\ MAF$

$Q_{20} = 1.77\ MAF$

$Q_{50} = 2.00\ MAF$

$Q_{100} = 2.20\ MAF$

ដែល MAF : ទឹកជំនន់មធ្យមប្រចាំឆ្នាំ (ម$^3$ / វិនាទី)

$Q_n$: ទឹកជំនន់ដែលសង្ឃឹមទុកថានឹងកើតមិនលើសពីម្តង រៀងរាល់ n ឆ្នាំជាមធ្យមភាគ

n : រយៈពេលខួប ( ឆ្នាំ) ។

ជាឧទាហរណ៍ ផ្ទៃរងទឹកភ្លៀងដែលប្រើប្រាស់ និង ទឹកជំនន់ដែលប៉ាន់ស្មានដោយវិធីសាស្ត្រនេះមានដូចខាងក្រោម :

**តារាង ទឹកជំនន់ ($Q_{10}$ និង $Q_{100}$)**

| ឈ្មោះខ្សែទឹក | ឈ្មោះអាងទឹក | ផ្ទៃរងទឹកភ្លៀង (គម$^2$) | ទឹកជំនន់ $Q_{10}$ (ម$^3$/វិ) | ទឹកជំនន់ $Q_{100}$ (ម$^3$/វិ) |
|---|---|---|---|---|
| ដូនភេ | ខ្ទប់ត្របែក | 137 | 128 | 184 |
| គ្រួច | អូរសារ៉ាយ | 51 | 53 | 76 |
| ត្រស់ | ទំនប់លោក | 332 | 284 | 409 |

### (3) រូបមន្ត Rational

រូបមន្ត Rational ត្រូវបានប្រើសំរាប់ស្ទឹងតូចរបស់ផ្ទៃរងទឹកភ្លៀងណាដែលតិចជាង 50គម² ។ ទឹកជំនន់ខ្ពស់បំផុតបានគណនាដោយសមីការដូចខាងក្រោម :

$$Q_{\max} = 1/3.6 \times f \times r_t \times A$$

ដែល: Qmax: ទឹកជំនន់ខ្ពស់បំផុត ( ម$^3$/វិ )

f : មេគុណរំហូរ ( មើលតារាងបន្ទាប់ )

**តារាង មេគុណហូរខ្លាំង**

| | |
|---|---|
| ប៉ានលេខាសាស្ត្រជម្រេលចោត | 0.75 - 0.9 |
| តំបន់ភ្នំ និង ព្រៃឈើ | 0.5 - 0.75 |
| ដីវាលកសិកម្ម | 0.45 - 0.6 |
| ដីស្រែក្រោមការស្រោចស្រព | 0.7 - 0.8 |
| ស្ទឹងតូចនៅទីវាល | 0.45 - 0.75 |
| ស្ទឹងភ្នំ | 0.75 - 0.85 |

$r_t$ : អាំងតង់ស៊ីតេទឹកភ្លៀង ( មម / ម៉.ត )

A: ផ្ទៃរងទឹកភ្លៀង (គម$^2$)

ពេលដែលទឹកជំនន់ប្រមូលផ្តុំដែលត្រូវដឹង ដើម្បីប៉ាន់ស្មានអាំងតង់ស៊ីតេទឹកភ្លៀងក្នុងកំឡុងពេលទឹកជំនន់ប្រមូលផ្តុំ ។

អាំងតង់ស៊ីតេទឹកភ្លៀង ជាញឹកញាប់ត្រូវបានប៉ាន់ស្មានដោយសមីការជាបន្តបន្ទាប់នៅពេលគ្មានទិន្នន័យអាំងតង់ស៊ីតេទឹកភ្លៀង ។

$$r_t = R_{24}/24 \times (24/T)^n$$

ដែល $r_t$: T - ម៉ោងអាំងតង់ស៊ីតេទឹកភ្លៀងអតិបរមា (មម / ម៉)

$R_{24}$: ទឹកភ្លៀងប្រចាំថ្ងៃ (មម)

n: 0.5～ 0.667. ជាទូទៅ 0.5 ត្រូវបានប្រើ ។

ពេលដែលទឹកជំនន់ប្រមូលផ្តុំត្រូវបានគណនាដោយសមីការរីហា (Rziha) ឬ សមីការហ៊្វុយគុយស៊ីម៉ា - ការដូយ៉ា (Fukushima-Kadoyo) ។

**សមីការរីហា**

$$T_a = 72 \times (h/l)^{0.6} \quad (\text{គម/ម៉})$$

ដែល $T_a$: ពេលទឹកជំនន់មកដល់

$l$: ប្រវែងស្ទឹងពីចំណុចប៉ាន់ស្មានទឹកជំនន់ទៅកន្លែងបញ្ចប់ផ្នែកខាងលើរបស់ជ្រលងភ្នំ (គម)

$h$: ភាពខុសគ្នានៃកំរិតកំពស់រវាង L - ប្រវែង (គម)

បើសមីការនេះ ឱ្យពេលទឹកជំនន់មកដល់តិចជាងមួយម៉ោង ពេលទឹកជំនន់មកដល់មួយម៉ោងនឹងត្រូវយក ។

**សមីការ ហ៊្វុយគុយស៊ីម៉ា ការដូយ៉ា**

$$t_p = C \times A^{0.22} \times r_e^{-0.35}$$

ដែល $C$: មេគុណដោយយោងទៅលើការប្រើប្រាស់ដីដូចខាងក្រោម :

តំបន់ភ្នំធម្មជាតិ = 250 ～ 350 = 290

តំបន់វាលស្មៅ 190 ～ 210 =200

ទីនេះ $C$ = 290 ត្រូវបានយក

$A$: ផ្ទៃរងទឹកភ្លៀង (គម²)

$r_e$: មធ្យមភាគទឹកភ្លៀងបានការក្នុងពេលទឹកជំនន់ប្រមូលផ្តុំ (មម / ម៉)

តារាងបន្ទាប់បង្ហាញពីការគណនាទឹកជំនន់សំរាប់អាងទឹកភ្លៀងអាង 160 ដោយអនុវត្តសមីការហ៊្វុយគុយស៊ីម៉ា-កាដូយ៉ា ។

## តារាង    ការគណនាទឹកជំនន់របស់អាងទឹក អាង 160 ខេត្តតាកែវ

អាង 160

| រយៈពេលខួប (ឆ្នាំ) | R24 (មម/ថ) | C | A (គម²) | rt (មម/ម៉) | re (មម/ម៉) | tp (នាទី) | d (ម៉) | n | f | Qp (ម³/វិ) |
|---|---|---|---|---|---|---|---|---|---|---|
| 100 | 147 | 290 | 2 | 20.09 | 14.07 | 133.90 | 2.23 | 0.5 | 0.7 | 7.81 |
| 20 | 118 | 290 | 2 | 15.39 | 10.78 | 146.99 | 2.45 | 0.5 | 0.7 | 5.99 |

### (4) វិធីសាស្ត្រឯកត្តាក្រាហ្វិកជលសាស្ត្រ (Unit Hydrograh Method)

វិធីសាស្ត្រឯកត្តាក្រាហ្វិកជលសាស្ត្រ ពឹងផ្អែកលើក្បួន ARD 1 ដែលត្រូវបានប្រើ និង យល់ព្រមទទួលនៅការិយាល័យបង្កើនល្បឿនអភិវឌ្ឍន៍ជនបទ (ARD) ក្រសួងមហាផ្ទៃ ប្រទេសថៃ បានប្រើសំរាប់ប៉ាន់ស្មានទឹកជំនន់សំរាប់ទន្លេតូចៗ ។ ពតិមានបន្ថែមទៀត អំពីទ្រឹស្តីបទត្រូវបានផ្តល់ឱ្យដោយការគ្រោងរបស់ទំនប់តូចៗ ឬ ផ្អែក 4 នៃជលសាស្ត្រ SCS ។ វិធីសាស្ត្រនេះត្រូវបានពន្យល់ដោយអនុវត្តតាមស្ទឹងត្រស់ (Tras Stream)-អាងទឹកទំនប់លោក ដូចជាសំណាកមួយដោយយោងទៅលើ "ក្បួនបណ្តុះបណ្តាលវិស្វកម្មអង្គភាពសន្តិភាពថៃឡង់ដ៏"

<u>ដំណាក់កាល 1</u>

ពី 1 : 100,000 ផែនទីឋានលេខាសាស្ត្រ សេចក្តីជាបន្តបន្ទាប់ត្រូវបានកំណត់ដំបូង ។ ផ្ទៃរងទឹកភ្លៀង (A) (332 គម²) ប្រវែងស្ទឹងបានវាស់ពីការដ្ឋានអាងទឹកនៅទីជម្រាលចែកទឹង (L) (25គម) ចំណុចកណ្តាលរបស់ផ្ទៃដោះទឹក (Coa) (Centroid of Drainage Area) ប្រវែងរបស់ស្ទឹងពីកន្លែងប្រសព្វរបស់បន្ទាត់គូស ពីចំណុចកណ្តាល (Lc) (12គម) ។

ជម្រេលមធ្យមរបស់ស្ទឹងនៅទីជម្រេលបានវាស់ពីខ្សែកូដដី (S) 0.00433 នៅក្នុងលក្ខណៈដែលកំរិតកំពស់នៅការដ្ឋានអាងទឹកទំនប់លោក គឺ 36.0 ម ហើយ កំរិតកំពស់នៅចំណុច 140 ម គឺ 24 000 ម ពីការដ្ឋានទំនប់លោក ។

ពេលមិនទាន់ដល់កំណត់ tlag ដែលត្រូវកំណត់ជាពេលពីចំណុចកណ្តាលរបស់ព្យុះទៅរំហូរខ្ពស់បំផុតរបស់ព្យុះនោះ ដែលគណនាដោយសមីការខាងក្រោម ។

$$t_{lag} = 1.90\left[\frac{LL_c}{\sqrt{S}}\right]^{0.162} = 7.44\,\text{hrs}$$

Tp = 1.11 x $t_{lag,}$, ជាទូទៅស្ថិតនៅរង្វង់ដែលជិតបំផុតកន្លះម៉ោង = 8.26 ម៉ =8.5 ម៉

Tp / 5 : ចន្លោះការបែងចែក ឬ រយៈពេលរបស់ព្យុះនីមួយៗ = 1.7 ម៉

ដំណាក់កាល 2

ទិន្នន័យទឹកភ្លៀងប្រចាំម៉ោងមិនអាចរកបាន ។ ពីទឹកភ្លៀងប្រចាំថ្ងៃដែលអាចកើតមានឡើង ($R_{24}$) ការចែកចាយប្រចាំម៉ោងត្រូវបានប៉ាន់ស្មានដោយសមីការខាងក្រោម ។

$$R_t = R_{24}\left(\frac{t}{24}\right)^k$$

ដែល $R_t$ : ទឹកភ្លៀងអតិបរមាក្នុងកំឡុងពេល t ម៉ោង

k : តំលៃថេរ 1/2~1/3, 1/2 គឺប្រើញឹកញាប់

បន្ទាប់មក ក្រាហ្វិកជលសាស្ត្រវំហូរព្យុះរង ត្រូវបានគិតពីការចែកចាយទឹកភ្លៀងប្រចាំម៉ោងដូចខាងក្រោម ។.

ជួរឈរ 1: Δ t ពេលជាម៉ោង (ពីការកំណត់ Tp/5)

ជួរឈរ 2: pt ទឹកភ្លៀង ដែលថែម១លើគ្នាជាសម ដែលគណនាដោយសមីការខាងលើ ។

ជួរឈរ 3: % ការថយចុះ ដោយសារការផ្លាស់ប្តូរ អាំងតង់ស៊ីតេព្យុះនៅលើតំបន់ជម្រាល (មើលរូបភាព 11.1)

ជួរឈរ 4: ជួរឈរ 2 * ជួរឈរ 3

ជួរឈរ 5: កំណើនទឹកភ្លៀង ឬ ទឹកភ្លៀងក្នុងកំឡុងពេល Δt នីមួយ ៗ

ជួរឈរ 6: ចំនួននៃជំរាប ARD សន្មត់ 0.3 សមក្នុងមួយម៉ោង ហើយដែលអត្រានៃជំរាបគឺថេរពាសពេញព្យុះ

ជួរឈរ 7: ជួរឈរ 5 – ជួរឈរ 6 = ផ្ទៃវំហូរ ។ តំលៃទាំងអស់នេះតំណាងឱ្យវំហូរពីព្យុះរងនីមួយ១ ។

ជួរឈរ 8: តំលៃពីជួរឈរ 7 បានកែសំរួលឡើងវិញដើម្បីទទួលសមាសធាតុមធ្យមរបស់ $Q_{peak}$. ។

ការគ្រោងរបស់ទំនប់តូច១បានរៀបចំជាលំដាប់ដោយតាមគំរូជាបន្តបន្ទាប់ : 6 4 3 1 2 5 ។

ដំណាក់កាល 3: កំណត់ឯកត្តាក្រាហ្វិកជលសាស្ត្រសំរាប់ទីជំរាលដែលគ្មានទំហំ

**តារាង ការគណនាវំពីទឹកភ្លៀងបានការ**

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 |
|---|---|---|---|---|---|---|---|
| ម៉ោង | សម | | សម | សម | សម | សម | សម |
| 0.0 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | - | 0.33 |
| 1.7 | 3.94 | 0.76 | 2.99 | 2.99 | 0.51 | 2.48 | 0.48 |
| 3.4 | 5.57 | 0.84 | 4.68 | 1.69 | 0.51 | 1.18 | 0.68 |
| 5.1 | 6.82 | 0.86 | 5.87 | 1.19 | 0.51 | 0.68 | 2.48 |
| 6.8 | 7.88 | 0.87 | 6.85 | 0.99 | 0.51 | 0.48 | 1.18 |
| 8.5 | 8.81 | 0.88 | 7.75 | 0.90 | 0.51 | 0.39 | 0.39 |
| 10.2 | 9.65 | 0.89 | 8.59 | 0.84 | 0.51 | 0.33 | |
| 11.9 | 10.42 | 0.90 | 9.38 | 0.79 | 0.51 | 0.28 | |
| 13.6 | 11.14 | 0.91 | 10.14 | 0.76 | 0.51 | 0.25 | |
| 15.3 | 11.82 | 0.92 | 10.87 | 0.73 | 0.51 | 0.22 | |
| 17.0 | 12.46 | 0.93 | 11.58 | 0.71 | 0.51 | 0.20 | |
| 18.7 | 13.06 | 0.93 | 12.15 | 0.57 | 0.51 | 0.06 | |

កូអ័រដោនេឯកត្តាក្រាហ្វិកជលសាស្ត្រ (DUH) ដែលនឹងបង្ហាញក្នុងរូបភាព 11.1 ។

ជួរឈរ 1: Δ t ពេលជាម៉ោង (ពីការកំណត់ Tp/5 )

ជួរឈរ 2: Δ t /Tp

ជួរឈរ 3: DUH អ័រដោនេពីក្រាហ្វិក

ជួរឈរ 4: DUH អ័រដោនេពីខ្ទង់ 3 ចែកនិង F ដែល

F = (0.36* Δ t * Σ DUH)/(ទីជំរាល, $km^2$) = 0.0123

F គឺគ្រាន់តែជាកត្តាបម្លាស់ប្តូរ ដែលផ្លាស់ប្តូរ DUH ទៅក្នុងតំលៃរំហូរដែលផ្អែកនៅលើ 1 សម នៃរំហូរសរុបសំរាប់ផ្តល់ឱ្យតំបន់ជំរាល និង Δ t ។ ចំពោះលទ្ធផលពិតដោយមិនគិតពីចំនួនរបស់ព្យុះរងដែលបានធ្វើវិភាគ តំលៃ DUH គួរបូកជាមួយកូអ័រដោនេនៅក្រោមខ្សែកោងទាំងមូល ។ ដោយមិនបញ្ចូលកូអ័រដោនេខ្សែ កោងទាំងមូលនៅក្នុងតំលៃ DUH ក៏រិតខ្ពស់បំផុតរបស់ធារទឹក និង កើតឡើង ។

**តារាង ឯកត្តាក្រាហ្វិកជលសាស្ត្រសំរាប់ទឹកភ្លៀងបានការ នៃ ១ សម**

| 1 | 2 | 3 | 4 |
|---|---|---|---|
| ម៉ោង | | | |
| 0.0 | 0.0 | 0.00 | 0.00 |
| 1.7 | 0.2 | 0.10 | 8.14 |
| 3.4 | 0.4 | 0.31 | 25.23 |
| 5.1 | 0.6 | 0.66 | 53.72 |
| 6.8 | 0.8 | 0.93 | 75.70 |
| 8.5 | 1.0 | 1.00 | 81.39 |
| 10.2 | 1.2 | 0.93 | 75.70 |
| 11.9 | 1.4 | 0.78 | 63.49 |
| 13.6 | 1.6 | 0.56 | 45.58 |
| 15.3 | 1.8 | 0.39 | 31.74 |
| 17.0 | 2.0 | 0.28 | 22.79 |
| 18.7 | 2.2 | 0.21 | 17.09 |
| 20.4 | 2.4 | 0.15 | 12.21 |
| 22.1 | 2.6 | 0.11 | 8.95 |
| 23.8 | 2.8 | 0.08 | 6.51 |
| 25.5 | 3.0 | 0.06 | 4.88 |
| 27.2 | 3.2 | 0.04 | 3.26 |
| 28.9 | 3.4 | 0.03 | 2.44 |
| 30.6 | 3.6 | 0.02 | 1.63 |
| 32.3 | 3.8 | 0.02 | 1.22 |
| 34.0 | 4.0 | 0.01 | 0.81 |
| | | | |
| សរុបរបស់ DUH | | 6.67 | |

**តំណាក់កាល** 4: កំណត់ក្រាហ្វិកជលសាស្ត្ររំហូរចូល (អ័រដោនេឯកត្តាក្រាហ្វិកជលសាស្ត្រ ពី ដំណាក់កាល 3 គុណនឹងរំហូរព្យុះរងពី ដំណាក់កាល 2 ) ។

# តារាង ព្យុះរង និង សមាសភាគក្រាហ្វិកជលសាស្ត្រ

| ពេលជាម៉ោង | ព្យុះរង | | | | | | សរុប |
|---|---|---|---|---|---|---|---|
| | 0.33 | 0.48 | 0.68 | 2.48 | 1.18 | 0.39 | |
| 0.0 | 0 | 0 | 0 | 0 | 0 | 0 | 0.0 |
| 1.7 | 2.66 | 0 | 0 | 0 | 0 | 0 | 2.7 |
| 3.4 | 8.23 | 3.88 | 0 | 0 | 0 | 0 | 12.1 |
| 5.1 | 17.53 | 12.02 | 5.52 | 0 | 0 | 0 | 35.1 |
| 6.8 | 24.70 | 25.59 | 17.11 | 20.21 | 0 | 0 | 87.6 |
| 8.5 | 26.56 | 36.07 | 36.43 | 62.67 | 9.57 | 0 | 171.3 |
| 10.2 | 24.70 | 38.78 | 51.33 | 133.42 | 29.66 | 3.15 | 281.0 |
| 11.9 | 20.71 | 36.07 | 55.19 | 188.00 | 63.15 | 9.77 | 372.9 |
| 13.6 | 14.87 | 30.25 | 51.33 | 202.15 | 88.99 | 20.79 | 408.4 |
| 15.3 | 10.36 | 21.72 | 43.05 | 188.00 | 95.69 | 29.30 | 388.1 |
| 17.0 | 7.44 | 15.12 | 30.91 | 157.68 | 88.99 | 31.50 | 331.6 |
| 18.7 | 5.58 | 10.86 | 21.52 | 113.20 | 74.64 | 29.30 | 255.1 |
| 20.4 | 3.98 | 8.14 | 15.45 | 78.84 | 53.59 | 24.57 | 184.6 |
| 22.1 | 2.92 | 5.82 | 11.59 | 56.60 | 37.32 | 17.64 | 131.9 |
| 23.8 | 2.12 | 4.27 | 8.28 | 42.45 | 26.79 | 12.29 | 96.2 |

ចំនួនខាងលើរបស់ជួរឈរនីមួយៗតំណាងឱ្យចំនួនលើសសំរាប់ព្យុះរងហូរគិតជាសម ។ ចំនួនដែលបានគណនានៅពីក្រោម ចំនួនទាំងអស់នេះតំណាងឱ្យធារទឹកព្យុះរងគិតជា ម³ /វិ ហើយក្រាហ្វិកខាងក្រោមតំណាងអោយលទ្ធផលរបស់ក្រាហ្វិកជលសាស្ត្រសំរាប់សមាសភាគព្យុះ ។ រំហូរមូលដ្ឋានមិនបានយកមកគិតក្នុងវិធីសាស្ត្រនេះទេ ។ ដូច្នេះរំហូរកំរិតខ្ពស់បំផុត គួរត្រូវបានកំណត់ដោយបន្ថែមរំហូរមូលដ្ឋានបើចាំបាច់ ។




រូបភាព ក្រាហ្វិករបស់ព្យុះរង និង សមាសភាគក្រាហ្វិកជលសាស្ត្រ

## (5) ការគណនាទឹកដោយរូបមន្តប្រតិបត្តិ (Manning Formula)

រូបមន្តប្រតិបត្តិបង្ហាញល្បឿនមធ្យម ជាមុខងាររបស់ភាពគ្រើមរបស់ប្រឡាយវង់ទឹក និង ចំណោតរបស់ថាមពលទឹកជម្រាល ។

$$V = \frac{1}{n} R^{2/3} I^{1/2}$$

$$Q = AV$$

ដែល V: ល្បឿនមធ្យម (ម. / វិ.)

n: មេគុណភាពគ្រើម

R: កាំអ៊ីដ្រូលិក = A/S (ម.)

I: ជម្រាលអេនែកជីអ៊ីដ្រូលិក

Q: ធារទឹក

A: ផ្ទៃពំនុះកាត់ទទឹង (ម$^2$)

S: បរិមាត្រដែលសើម (ម.)

បើផ្ទៃទឹកហូររបស់ស្ទឹងអាចត្រូវបានពន្យល់ច្បាស់លាស់ នៅក្នុងទីកន្លែងដែលទន្លេហូរចូលជ្រលងជ្រោះ យើងអាចប៉ាន់ស្មានពីកំពស់ទឹកអតិបរមាកន្លងមកពីស្លាកទឹកជំនន់ ការកែប្រែសារពើរុក្ខជាតិ និង សម្ភាសជាមួយអ្នកស្រុកនៅតាមកន្លែងដែលទៅដល់ ។ កំពស់ទឹកជំនន់អតិបរមា ពីមុនបានចង្អុលប្រាប់ដោយអ្នកស្រុកគួរត្រូវបានវាស់ជាមួយគ្នានឹងពំនុះកាត់ទទឹងទន្លេ ដោយឧបករណ៍វាស់ស្ទង់ ។ ពីការស្រាវជ្រាវទាំងអស់នេះ យើងអាចដឹងពីផ្ទៃពំនុះកាត់ទទឹងរបស់រំហូរ (A) និង ជំរាលអ៊ីដ្រូលិក (I) ។

### តារាង មេគុណភាពគ្រើម

| សំភារៈ និង លក្ខខណ្ឌរបស់ប្រឡាយទឹក | | មេគុណភាពគគ្រើម | | |
|---|---|---|---|---|
| | | អប្ប . | មធ្យម | អតិ |
| ស្ទឹងតូចក្នុងទីវាល | | | | |
| 1. | គ្មានស្មៅ ត្រង់ គ្មានអន្លង់ជ្រៅនៅពេលកំពស់ទឹកពេញ | 0.025 | 0.030 | 0.033 |
| 2. | ដូច និងថ្មនិង មានស្មៅ | 0.030 | 0.035 | 0.040 |
| 3. | ភក់ | 0.033 | 0.040 | 0.045 |
| 4. | ដូច និង ថ្មខ្លះ និង ស្មៅ | 0.035 | 0.045 | 0.050 |
| 5. | ដូច និង មានការប្រែប្រួលច្រើននៃជម្រាលនិង ពំនុះកាត់ទទឹង | 0.040 | 0.048 | 0.055 |
| 6. | ដូច ក្នុងសេចក្តី 4 ប៉ុន្តែមានថ្មច្រើន | 0.045 | 0.050 | 0.060 |
| 7. | ស្មៅ និង អន្លង់ជ្រៅក្នុងរំហូរមកដល់តិចៗ | 0.050 | 0.070 | 0.080 |
| 8. | ។ល។ | 0.075 | 0.100 | 0.115 |
| ស្ទឹងនៅក្នុងតំបន់ភ្នំ មានដំណាំតូចៗបន្តិចបន្តួចនៅបាតស្ទឹង ច្រាំងស្ទឹងមានជំរាលចោត ។ ដើមឈើ និង ព្រៃគម្ពោតនៅតាមច្រាំងត្រូវបានលិចទឹកនៅពេលមានព្យុះ | | | | |
| 1. | ដុំថ្ម និង គ្រួសនៅបាតស្ទឹង | 0.030 | 0.040 | 0.050 |
| 2. | ដុំថ្មធំៗ | 0.040 | 0.050 | 0.070 |
| ស្ទឹងធំ | | | | |
| 1. | ពំនុះកាត់ទទឹងទៀងទាត់ដោយគ្មានដុំថ្មធំៗ និង គ្មានដើមឈើ និង ព្រៃគម្ពោត | 0.025 | | 0.060 |
| 2. | ពំនុះកាត់ទទឹងគ្រើមមិនទៀងទាត់ | 0.035 | | 0.100 |

## 11.3 គុណភាពទឹក

pH និង ភាពប្រៃត្រូវបានត្រួតពិនិត្យសំរាប់គោលបំណងនៃការស្រោចស្រព និង វត្ថុផ្សេងៗទៀតដែលនឹងត្រូវវាយតំលៃជាទឹកផឹក ។ ស្តង់ដារគុណភាពទឹកតាមមុខនីមួយៗមានបង្ហាញក្នុងតារាង 11.1 ។

ពីទស្សនៈរបស់គុណភាពទឹកស្រោចស្រព (យោងលើតំលៃស្តង់ដារ FAO ក្នុងតារាង 11.1)បញ្ហាដី និងការដាំដុះដែលជាបទពិសោធធម្មតា ឬដែលបានយល់ដឹងនៅពេលទឹកត្រូវបានប្រើតិចជាងតំលៃ FAO ដែលបានបង្ហាញដូចជា "គ្មានកំរិតនៃការកំហិតកំណត់លើការប្រើប្រាស់" ។ ជាមួយនឹងកំហិតកំណត់បន្តិចបន្តួចដើម្បីសំរាលកំរិតការយកចិត្តទុកដាក់នឹងកើតឡើងជាបណ្តើៗក្នុងការជ្រើសរើសដំណាំ និង ជំរើសការគ្រប់គ្រង និង ត្រូវការប្រសិនបើសក្តានុពលទិន្នផលពេញលេញនឹងត្រូវបានសំរេច។ នៅពេលដែលទឹកត្រូវបានប្រើដែលវាស្មើ ឬលើសទៅនឹងតំលៃដែលបានបង្ហាញដូចជាការកំហិតកំណត់ដ៏តឹងរឹង អ្នកប្រើប្រាស់ទឹកនឹងពិសោធន៍បញ្ហាដី និងការដាំដុះ ឬ ទិន្នផលដែលថយចុះ ។ អាស្រ័យដូចនេះបើតំលៃគុណភាពទឹកដែលបានរកឃើញដូចការប្រើប្រាស់ស្រោចស្រពដែលកំហិតកំណត់ វាត្រូវបានយល់ព្រមថាជាលំដាប់លំដោយនៃការសិក្សាសំរាប់ពិសោធកសិកម្មដែលត្រូវធ្វើដើម្បីកំណត់ពីបច្ចេកទេសកសិកម្ម និង ការដាំដុះ ដែលនឹងត្រូវអនុវត្តមុនពេលការចាប់ផ្តើមប្រើប្រាស់ទឹកក្នុងគំរោង ។

ដើម្បីលៃលកដោះស្រាយបញ្ហាជាតិប្រៃ ដែលបានសង្កេតឃើញម្តងម្កាលនៅក្នុងប្រព័ន្ធស្រោចស្រពដែលជន់លិច ជំរើសគ្រប់គ្រងមួយចំនួនសំរាប់ត្រួតពិនិត្យជាតិប្រៃអាចបានជាបន្តបន្ទាប់ :

- កែលំអសំណង់ដោះទឹកដើម្បីត្រួតពិនិត្យ និង ធ្វើឱ្យរាក់ នឹង
- គ្រងទឹកដើម្បីត្រួតពិនិត្យអំបិលដែលរលាយដោយអនុវត្តន៍ការបន្ថែមទឹក
- កែលំអការអនុវត្តន៍កសិកម្ម ការដាំដុះ (ការធ្វើដីឱ្យស្មើ ឬ ជាថ្នាក់ៗ ពេលវេលានៃការស្រោចស្រព ការទុកពូជការប្រើជី កសិកម្មទីជំរៅ ។ល។)
- ផ្លាស់ប្តូរ ឬ ការផ្គត់ផ្គង់ទឹកចំរុះ
- ការត្រួតពិនិត្យ និង ការអនុវត្តន៍ដំណាំគ្មានអំបិល

ពីទស្សនៈនៃទឹកផឹក គោលការណ៍ជាមូលដ្ឋាន គឺដើម្បីថែទាំគុណភាពទឹកដែលមានស្រាប់ទៅកាន់ទំហំដែលអាចធ្វើបាន តាំងតែពីទឹកត្រូវប្រើប្រាស់ជាទូទៅ សំរាប់ទាំងពីរយ៉ាងគឺការស្រោចស្រព និង សំរាប់ផឹក ឬ ជាប្រយោជន៍ក្នុងស្រុក ។ នេះមានន័យថាផែនការ និង ការអនុវត្តន៍កសិកម្ម ការដាំដុះគួរត្រូវយកចិត្តទុកដាក់ដោយប្រុងប្រយ័ត្នដើម្បីកុំឱ្យទៅជាមូលហេតុនៃការធ្វើឱ្យទឹកក្រខ្វក់យ៉ាងធ្ងន់ធ្ងរដូចជា :

- សារធាតុក្រខ្វក់ភាគច្រើនបណ្តាលដោយកាកសំណល់កសិកម្ម ឬ ល្បាយជី
- ការធ្វើឱ្យក្រខ្វក់ដោយមេរោគភាគច្រើន គឺបណ្តាលមកពីកំណើននៃការចិញ្ចឹមបសុសត្វ និង
- ការធ្វើឱ្យក្រខ្វក់ដោយជាតិពុលភាគច្រើនបណ្តាលមកពីថ្នាំគីមីកសិកម្ម ។

# ជំពូក 12 កសិកម្ម

## 12.1 ដំណើរផែនការលើកម្មវិធីស្រោចស្រពកសិកម្ម

ដំណើរផែនការលើកម្មវិធីកសិកម្មសំរាប់គំរោងស្រោចស្រពបង្ហាញដូចខាងក្រោមនេះ :




រូបភាព ដំណើរការលើកម្មវិធីស្រោចស្រពកសិកម្ម

## 12.2 ការជ្រើសរើសដំណាំគោលដៅ

ដំណាំគោលដៅដែលនឹងស្រោចស្រពក្នុងតំបន់គំរោង គួរជ្រើសរើសដោយត្រួតពិនិត្យគ្រប់ជ្រុងជ្រោយនូវចំណុចដូចខាងក្រោមនេះ :

1) ស្ថានភាពធម្មជាតិ អាកាសធាតុ និង ដីដាំដំណាំក្នុងតំបន់គំរោង
2) ប្រភពទឹកស្រោចស្រពដែលអាចរកបាន
3) ស្ថានភាពសង្គម និង សេដ្ឋកិច្ច លទ្ធភាពរកប្រាក់ចំណេញ និង លទ្ធភាពរកទីផ្សារសំរាប់កសិផលសន្តិសុខស្បៀងនៅក្នុងជុំវិញតំបន់គំរោងកំលាំងពលកម្មដែលអាចរកបាន សត្វអូសទាញ និង ទុនចំណាយដែលត្រូវការ
4) ស្ថានភាពដែលកសិករទទួលផលប្រយោជន៍ការយល់ដឹង និង ចំណង់ចំពោះការដាំដុះ កំរិតជំនាញធ្វើស្រែ និង សមត្ថភាពហិរញ្ញវត្ថុសំរាប់វិនិយោគចំពោះទុនចំណាយដែលត្រូវការ និង
5) លទ្ធភាពសំរាប់ទ្រទ្រង់កម្មវិធី ដូចជា សេវាកម្មផ្សព្វផ្សាយ ការផ្គត់ផ្គង់ ទុនចំណាយ ឥណទាន និង ទីផ្សារ

ចំពោះការត្រួតពិនិត្យបញ្ហាខាងលើ ចាំបាច់ណាស់ត្រូវដឹងពីបរិស្ថានវិទ្យា និង លក្ខណៈបច្ចេកទេសកសិកម្មរបស់កសិផលជ្រើសរើសក៏ដូចជាទិន្នន័យ និង ពត៌មានពីការស្ទង់មតិស្តីពីស្ថានភាពបច្ចុប្បន្នរបស់សេដ្ឋកិច្ចសង្គម និង កសិកម្ម ដូចដែលបានបញ្ជាក់ក្នុងផ្នែកទី 1 នៃគោលការណ៍ណែនាំនេះ ។ ដំណាំគោលដៅគួរជ្រើសរើសដោយសហប្រតិបត្តិការជាមួយសេដ្ឋកិច្ចវិទូ កសិត្រវិទូ និង មន្ត្រីផ្សព្វផ្សាយរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ (MAFF) និងគំនិតព្រមទាំងអនុសាសន៍របស់អ្នកស្រាវជ្រាវកសិកម្មផងដែរ ។ ដំណាំសំខាន់ដែលជ្រើសរើស គឺស្រូវដោយធ្វើការពិចារណាពីស្ថានភាពតំបន់ជនបទកម្ពុជា សំរាប់ទទួលបានស្បៀងគ្រប់គ្រាន់ និងការយល់ដឹងពីកសិករនាពេលបច្ចុប្បន្ននេះ ។ ស្បៀងគ្រប់គ្រាន់នៅលំដាប់ថ្នាក់ជាតិដែលសំរេចបានតាមការបង្កើនផលិតកម្មស្រូវ ។ ទោះបីជាយ៉ាងណាក៏ដោយស្ថេរភាពស្បៀងគ្រប់គ្រាន់នោះមិនទាន់គួរជាទីពេញចិត្តនៅឡើយទេ ។ នៅតែមានតំបន់ជាច្រើននៅក្នុងប្រទេសមានការខ្វះខាតស្រូវ និងចំនួនប្រជាពលរដ្ឋនៅតែមានអត្រាកំណើនខ្ពស់ដដែល ។ ស្រូវនៅតែជាដំណាំសំខាន់បំផុតសំរាប់គំរោងស្រោចស្រព ។ ដោយស្រូវមានច្រើនពូជ ការត្រួតពិនិត្យពូជ វាចាំបាច់ដែលតំរូវឱ្យមានការជ្រើសរើសពូជ ពូជក្នុងស្រុក (រយៈពេលដាំដុះយូរអង្វែង) ឬ ពូជស្រូវដែលផ្តល់ទិន្នផលខ្ពស់ (រយៈពេលដាំដុះខ្លីជាង) ការគិតលើរយៈពេលអាចស្រោចស្រព តំលៃនៅទីផ្សារ និង គោលបំណងរបស់កសិករ ។

ម្យ៉ាងវិញទៀតការណែនាំអំពីដំណាំសំរាប់លក់ គឺដំណាំរួមផ្សំ រួមមានបន្លែផង នឹងមានសារៈសំខាន់ដើម្បីកែលំអស្ថានភាពសេដ្ឋកិច្ចកសិករ ។ ដំណាំទាំងអស់នោះនឹងនាំយកប្រាក់ចំណូលបន្ថែមទៀតដល់កសិករ ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើអោយមានដំណាំច្រើនមុខគួរកំណត់ទៅតាមតំរូវការរបស់ទីផ្សារ សក្តានុភាពកសិកម្ម និង ការអនុវត្តន៍ការដាំដុះថ្មីៗដែលបានធ្វើ ។

ដំណាំគោលដៅនឹងត្រូវជ្រើសរើសចេញពីកសិផល ដែលបានស្នើជាច្រើនដែលដាំនៅពេលបច្ចុប្បន្នក្នុង និង ជុំវិញតំបន់គំរោងដែលកសិករទទួលផលប្រយោជន៍ចង់ធ្វើ និងបានគិតគូរដល់ស្ថានភាពសមស្របក្នុងតំបន់

គំរោង ។

មុខដំណាំដែលពិនិត្យសំរាប់ការជ្រើសរើសក្នុងដំណាំគោលដៅមានបង្ហាញក្នុងតារាង 12-1 និង សំណាកលទ្ធផលការត្រួតពិនិត្យសំរាប់ការជ្រើសរើសកសិផលមានបង្ហាញក្នុងតារាង 12-2 ។

## 12.3 ការរៀបចំគំរូដាំដុះដែលបានស្នើ

តារាងពេលវេលាដាំដុះដំណាំគោលដៅ ដែលជ្រើសរើសរួចសំរាប់កសិកម្មស្រោចស្រពមានបង្ហាញក្នុងទម្រង់ (រូបភាព)"គំរូដាំដុះ" ។ គំរូដាំដុះបង្ហាញពីផែនការដាំដុះក្នុងបែបបទសាមញ្ញដោយមាន i) ឈ្មោះដំណាំ ii) ផ្ទៃដីដាំដុះ iii) រដូវដាំដុះ និង រយៈពេលដាំដុះ iv) ការចាប់ផ្តើម និង បញ្ចប់ការដាំដុះ និង ការច្រូតកាត់ v) រយៈពេលរៀបចំដី បណ្តុះ ។

ដំណាំគំរូត្រូវពិនិត្យ ការយកចិត្តទុកដាក់ពីស្ថានភាពអាកាសធាតុពេលច្រូតកាត់ និង រយៈពេលហាល ក៏ដូចជាការរកកំលាំងពលកម្ម សត្វអូសទាញ និង គ្រឿងយន្តកសិកម្មផងដែរ ។ ដំណាំគំរូដែលបានស្នើឡើងនឹងត្រូវបញ្ចប់ក្រោយពេលត្រួតពិនិត្យពីតុល្យភាពទឹកដែលរកបាន និង តំរូវការ ដូចដែលបានបញ្ជាក់ក្នុងផ្នែក 11-1 "ទឹកដែលអាចរកបាន" ។

សំណាករបស់ដំណាំគំរូបានស្នើឡើង ដែលឈរលើមូលដ្ឋាននៃដំណាំគំរូបច្ចុប្បន្ននៅក្នុងតំបន់គំរោង មានបង្ហាញក្នុងរូបភាព 12.1 ។

## 12.4 ការប៉ាន់ស្មាន ទិន្នផលដែលបានកំណត់

ទិន្នផលរំពឹងទុករបស់ដំណាំគោលដៅស្ថិតក្រោមស្ថានភាពស្រោចស្រព និង ធ្វើការប៉ាន់ស្មានដោយយោងលើទិន្នន័យ និង ពត៌មានដូចមានខាងក្រោម :

- បង្ហាញកំរិតទិន្នផលដោយការស្រោចស្រពក្នុង និង ជុំវិញតំបន់សិក្សា
- ទិន្នផលក្នុងឆ្នាំដែលមាន អាកាសធាតុអំណោយផលល្អ ( ទឹកភ្លៀង ) ក្នុង និង ជុំវិញតំបន់គំរោង
- គំនិតរបស់ភ្នាក់ងារផ្សព្វផ្សាយ និង ក្សេត្រវិទូរបស់ MAFF (DAFF)
- ទិន្នផលដែលធ្វើសាកល្បងពីស្ថានីយស្រាវជ្រាវកសិកម្ម
- លទ្ធភាពសកម្មភាពផ្សព្វផ្សាយ និង កម្មវិធីទ្រទ្រង់ដទៃទៀតក្នុង និង ជុំវិញតំបន់គំរោង និង
- លទ្ធភាពកែលំអការអនុវត្តន៍កសិកម្មដូចជា ការប្រើប្រាស់ពូជល្អ ការប្រើជី និង ការការពារដំណាំ

កត្តាទាំងនេះមានសារៈសំខាន់ណាស់ ដែលទិន្នផលបានរំពឹងទុកនោះជាទិន្នផលមធ្យម ដែលបានកំណត់បន្ទាប់ពីការបញ្ចប់ការសាងសង់សំណង់ស្រោចស្រពពីគំរោង ។ ទិន្នផលនឹងកើនឡើងដោយសន្សឹម១បន្ទាប់ពីការចែកចាយដោយគំរោងទៅតាមការកែលំអជំនាញដាំដុះរបស់កសិករ និង សេវាទ្រទ្រង់តាមធម្មតាវានឹងត្រូវចំណាយពេលអស់ជាច្រើនឆ្នាំ ដើម្បីសំរេចឱ្យបានទូវទិន្នផលដែលបានកំណត់នោះ ។

ទិន្នផលដែលបានកំណត់របស់ស្រូវដែលមានទឹកស្រោចស្រពក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ នៅកម្ពុជាត្រូវបានប៉ាន់ស្មានត្រួស១លើមូលដ្ឋានស្ថានភាពបច្ចុប្បន្នផលិតកម្មស្រូវមានបង្ហាញក្នុងតារាងខាងក្រោម:

**តារាង 12.3 ទិន្នផលស្រូវដែលរំពឹងទុក ក្នុងគំរោងស្រោចស្រព**

| ពូជ | រដូវប្រាំង | រដូវវស្សា |
|---|---|---|
| ពូជទិន្នផលខ្ពស់ (HYV) | 3 - 4 តោន/ហ.ត | 3 – 3,5 តោន/ហ.ត |
| ពូជក្នុងស្រុក | 2,5 – 3,5 តោន/ហ.ត | 2 - 3 តោន/ហ.ត |

## 12.5 ការវិភាគថវិកាកសិផល

ថវិកាកសិផលស្នើឡើង បង្ហាញពីចំនួនប្រាក់ចំណូលដុលពីផលិតផល ចំណាយផលិតកម្ម និង ចំណេញសុទ្ធក្នុងមួយឯកត្តាដី (ហ.ត) លើដំណាំនីមួយៗសំរាប់ផែនការអនាគត ។ ថវិកាដំណាំ ផ្តល់ទិន្នន័យគ្រឹះ សំរាប់ធ្វើការប៉ាន់ស្មានអត្ថប្រយោជន៍ស្រោចស្រពពីផលិតកម្មកសិផល និង សេដ្ឋកិច្ចកសិករដែលរំពឹងទុក ។ លទ្ធភាពរកប្រាក់ចំណេញពីកសិផល អាចប៉ាន់ស្មានបានដោយការប្រៀបធៀបថវិកាដំណាំ ។ តារាង 12-4 បង្ហាញសំណាករបស់ថវិកា ដំណាំស្នើរឡើង ដោយប្រៀបធៀបជាមួយស្ថានភាពបច្ចុប្បន្ន។ ចំណូលដុលរបស់ ថវិកាដំណាំដែលស្នើរឡើង បានបង្ហាញពីមូលដ្ឋានទិន្នផលកសិផលដែលរំពឹងទុក និង តំលៃផលិតផលនៅ កសិដ្ឋាន ។

ចំណាយផលិតកម្មផ្ទាល់ស្ថិតលើបរិមាណដែលត្រូវការ និង តំលៃឯកត្តាសំរាប់ទុនចំណាយការជួល កំលាំងពលកម្ម សត្វអូសទាញ និង ចំណាយផ្សេងៗទៀត ។ ចំណាយសំរាប់កំលាំងពលកម្មក្នុងគ្រួសារ ជាទូទៅមិនគិតបញ្ចូលក្នុងចំណាយផលិតកម្មទេ ។ ចំណាយប្រយោលរួមមានពន្ធលើដីស្រែ និង ផលិតផល ចំណាយរំលោះថ្លៃប្រើប្រាស់ទឹក និង ថ្លៃឈ្នួលដី ។

## 12.6 ការត្រួតពិនិត្យ ទុនចំណាយ និង កំលាំងពលកម្មដែលត្រូវការ

លទ្ធភាពអាចរកបានទុនចំណាយដែលត្រូវការ សំរាប់កម្មវិធីផលិតកម្មកសិកម្មដែលស្នើឡើងគួរត្រួត ពិនិត្យទិដ្ឋភាពនៃទីផ្សារផ្គត់ផ្គង់បរិមាណ គុណភាព រដូវផ្គត់ផ្គង់ និង តំលៃ ។ បើសិនជាមានបញ្ហាខាងការ ផ្គត់ផ្គង់ទុនចំណាយផែនការផលិតកម្មមិនអាចដំណើរការបានទេ ។ ក្នុងករណីនេះ អាចមានការផ្លាស់ប្តូរ ផែនការ ឬក៏ការផ្តល់កម្មវិធីទ្រទ្រង់ផងដែរ ។ ឧទាហរណ៏កម្មវិធីផលិតកម្មពូជស្រូវសំរាប់ការខ្វះខាតពូជល្អ និង កម្មវិធីដឹកជញ្ជូនជីទៅក្នុងតំបន់គំរោងដោយមានការលំបាកក្នុងការដឹកជញ្ជូនជី ។ គំរូនៃការប៉ាន់ស្មានតំរូវការ ទុនចំណាយមានបង្ហាញក្នុងតារាង 12.4 ។

តំរូវការកំលាំងពលកម្មសំរាប់កម្មវិធីផលិតកម្មកសិកម្ម ជាទូទៅ មានការកើនឡើងបើប្រៀបនឹង ស្ថានភាពបច្ចុប្បន្ន ។ តុល្យភាពកំលាំងពលកម្មដែលអាចរកបាន គួរត្រួតពិនិត្យដោយប្រុងប្រយ័ត្នសំរាប់រដូវ មមាញឹកបំផុត គឺរយៈពេលដកស្ទូង និង រយៈពេលច្រូតកាត់ ។ កំលាំងពលកម្មដែលអាចរកបានសំរាប់ការងារ ក្នុងកសិដ្ឋានអាចប៉ាន់ស្មានពីការប្រើកំលាំងពលកម្មជាមធ្យមក្នុងគ្រួសារនីមួយៗ កំលាំងពលកម្មអាចធ្វើការ បាននៅកសិដ្ឋាន និងចំនួនថ្ងៃធ្វើការ ។ កំលាំងពលកម្មគ្រួសារខ្លះ មិនធ្វើស្រែចំការទេ ដូចជាអ្នកខ្លះនៅផ្ទះ មើលកូន ចិញ្ចឹមសត្វ លក់ដូរនៅផ្សារ .....។ល។

គំរូការត្រួតពិនិត្យតុល្យភាពកំលាំងពលកម្មតាមខែ មានបង្ហាញក្នុងតារាង 12.5 ។

បើសិនតំរូវការកំលាំងពលកម្មក្នុងរដូវមមាញឹកបំផុតមិនគួរឱ្យពេញចិត្តយន្តកម្មការអនុវត្តន៍កសិកម្ម ឬ អាច ការជួលកំលាំងពលកម្មមកពីខាងក្រៅបាន ។

## 12.7 ផលិតកម្មដំណាំដែលរំពឹងទុក និង ប្រាក់ចំណេញសុទ្ធ

### 12.7.1 ផលិតកម្មដំណាំដែលរំពឹងទុក

ផលិតកម្មដំណាំរំពឹងទុកដោយគំរោង អាចប៉ាន់ស្មានពីផ្ទៃដីដាំដុះដែលបានស្នើរ និង ឯកត្តាទិន្នផល ។ កំណើនផលិតកម្មដោយគំរោងបានផ្តល់ស្ថានភាពខុសគ្នាពីរយ៉ាង "ស្ថានភាពមានគំរោង" (ផែនការដែលស្នើរឡើង) និង "ស្ថានភាពគ្មានគំរោង"(1) ។ សំណាកផលិតកម្មដំណាំដែលរំពឹងទុកមានបង្ហាញក្នុងតារាង 12.6 ។

### 12.7.2 ការវិភាគសន្តិសុខស្បៀង

ការវិភាគពីតំរូវការ និង ការផ្គត់ផ្គង់ផលិតផលលើផែនការអនាគតគឺចាំបាច់ណាស់សំរាប់វាយតំលៃសន្តិសុខស្បៀងក៏ដូចជាផែនការទីផ្សារផលិតផលផងដែរ ។ និតិវិធីវាយតំលៃទាំងនេះបង្ហាញដូចខាងក្រោមនេះ

(1) **តុល្យភាពស្បៀង**

វាជាប្រការចាំបាច់ក្នុងការវិភាគតុល្យភាពស្បៀង សំរាប់គំរោងផលិកម្មស្រូវជាពិសេសសំរាប់គំរោងមានគោលបំណងកែលំអសន្តិសុខស្បៀង ឬ ស្រូវដែលលើសពីសេចក្តីត្រូវការនៅទីផ្សារ ។ សន្តិសុខស្បៀងក្នុង និង ជុំវិញតំបន់គំរោងនឹងបានត្រួតពិនិត្យ ។ សន្ទស្សន៍របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ (MAFF) ដូចខាងក្រោម :

**តារាង 12.8 ស្តង់ដារសន្ទស្សន៍សំរាប់ការត្រួតពិនិត្យសន្តិសុខស្បៀង**

| | |
|---|---|
| 1. តំរូវការអង្ករជាមធ្យមក្នុងម្នាក់ៗ | 151.2 គក្រ |
| 2. អត្រាប្រមូលបានពីរោងកិនស្រូវ | 62% |
| 3. តំរូវការស្រូវក្នុងម្នាក់ៗ (1) / (2) | 244 kg |
| 4. បាត់បង់ក្រោយពេលច្រូតកាត់ និង ទុកធ្វើពូជ | 17% នៃផលិតកម្ម |
| 5. តំរូវការផលិតកម្មស្រូវក្នុងម្នាក់ៗ (3) / (100% - (4)) | 294 គក្រ |

*ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ*

នៅក្នុងការប៉ាន់ស្មានខាងលើ ចំនួនប្រជាជននៅក្នុងតំបន់កំណត់នៅឆ្នាំកំណត់គួរ ព្យាករណ៍ដោយផ្អែកលើអត្រាកំណើនចំនួនប្រជាជន ។ ក្នុងគំរោងទាំងនេះ មានសារៈសំខាន់ណាស់ដើម្បីប៉ាន់ស្មានតើមានកំណើនសន្តិសុខស្បៀងប៉ុន្មានភាគរយបានកែលំអ ឬ តើចំនួនស្រូវលើសប៉ុន្មានដែលត្រូវយកទៅលក់នៅទីផ្សារ ។

---

(1) "ស្ថានភាពគ្មានគំរោង" គឺមិនដូចស្ថានភាពបច្ចុប្បន្នទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពបច្ចុប្បន្ន អាចអំណោយផលដល់ស្ថានភាពគ្មានគំរោង ប្រសិនបើការប៉ាន់ស្មានភាពទាំងពីរគឺ "បច្ចុប្បន្ន" ។

(2) **ការវិភាគពីការផ្គត់ផ្គង់ និង តំរូវការអំពីដំណាំសំរាប់លក់**

ការវិភាគតុល្យភាពតំរូវការ និង ការផ្គត់ផ្គង់ដំណាំសំរាប់លក់ គឺមានសារៈសំខាន់សំរាប់ការធ្វើផែនការទីផ្សារផលិតផលនាពេលអនាគត ។ ការត្រួតពិនិត្យនឹងធ្វើទៅលើតំបន់ទីផ្សារផលិតផលដែលកំណត់នៅក្នុងតំបន់គំរោង តំបន់ជនបទក្នុង និង ជុំវិញតំបន់គំរោងនៅជិតទីប្រជុំជនទីក្រុង ឬ ទីក្រុងធំៗ ។ ការធ្វើវិភាគនេះបានពិនិត្យលើទីផ្សាររួមមាន ច្រកទីផ្សារកំណត់ស្ថានភាព និង ទំហំទីផ្សារ និង តុល្យភាពផ្គត់ផ្គង់តំរូវការប្រែប្រួលថ្លៃផលិតផល ក៏នឹងត្រូវត្រួតពិនិត្យដែរ ។

## 12.7.3 ប្រាក់ចំណេញហិរញ្ញវត្ថុស្រោចស្រព

ប្រាក់ចំណេញហិរញ្ញវត្ថុស្រោចស្រព ដោយផលិតកម្មកសិកម្មបានផ្តល់ការខុសគ្នារវាងប្រាក់ចំណេញសុទ្ធសរុបដោយមានគំរោង និង គ្មានគំរោង នឹងគឺប្រាក់ចំណេញដែលកើនឡើង ។ តារាងបង្ហាញគំរូនៃការវិភាគប្រាក់ចំណេញដែលកើនឡើង ។

## 12.7.4 ការវិភាគសេដ្ឋកិច្ចគ្រួសារ

ប្រាក់ចំណេញបានពីកសិផលដោយគំរោងស្រោចស្រពនឹងបង្កើនប្រាក់ចំណេញដល់កសិករ ។ ការវិភាគសេដ្ឋកិច្ចគ្រួសារធ្វើឡើងដើម្បីវាយតំលៃនៃគំរោងស្រោចស្រពដល់សេដ្ឋកិច្ចគ្រួសារ ។

តារាង 12.7 បង្ហាញពីការប៉ាន់ស្មានចំណូលសរុប ចំណាយផលិតកម្ម ប្រាក់ចំណេញសុទ្ធ និង ចំណេញសុទ្ធកើនឡើងតាមរបស់កសិដ្ឋានទំហំមធ្យម ។

# 12.8 ផែនការកែច្នៃកសិផលក្រោយពេលច្រូតកាត់ និង ទីផ្សារ

កម្មវិធីទ្រទ្រង់គួរគិតដល់ការកែច្នៃកសិផលក្រោយពេលច្រូតកាត់ និង ទីផ្សារដើម្បីធានាឱ្យបានកំណើនប្រាក់ចំណេញរបស់អ្នកផលិតតាមការប្រមើលទុកក្នុងផែនការផលិតកម្មកសិកម្ម ។ ដោយផ្អែកលើសេដ្ឋកិច្ចទីផ្សារសេរី ផលិតផលកសិកម្មបានដឹកជញ្ជូនពីតំបន់ផលិតជាច្រើនកន្លែង និងបាននាំចូលពីប្រទេសវៀតណាម នឹងថ្លៃដោយធ្វើការប្រកួតប្រជែងគ្នាក្នុងទីផ្សារកម្ពុជា ។ ដូច្នេះហើយយើងត្រូវយល់ឱ្យបានច្បាស់ថាគ្មានផលិតផលណាធានាការលក់ឱ្យពេញនិយមនៅផ្សារ បើផលិផលនោះមិនមានភាពខ្លាំងក្លាជាងគេ ក្នុងការប្រកួតប្រជែង និង បំពេញតំរូវការទីផ្សារទេនោះ ។ បន្ទាប់មកកម្មវិធីជួយទ្រទ្រង់ទីផ្សារជាកម្មវិធីមួយដែលគួរឱ្យចង់បានពីសំណាក់អ្នកផលិតដើម្បីបំពេញឱ្យប្រសិទ្ធិភាពសេដ្ឋកិច្ចតាមផែនការផលិតកម្មកសិកម្មដែលកម្មវិធីទ្រទ្រង់គួរធ្វើឡើងដោយអាស្រ័យលើផែនការផលិតកម្មកសិកម្មដូចមានបង្ហាញខាងក្រោម :




**រូបភាព ដំណើរផែនការក្រោយពេលប្រមូលផល និង កែច្នៃ**

ដើម្បីអនុវត្តកម្មវិធីទ្រទ្រង់ទាំងអស់នេះ សំភារៈដូចជា ឥណទាន ប្រដាប់ប្រដា និង ឧបករណ៍ ព្រមទាំងការបណ្តុះបណ្តាល គឺជាប្រការចាំបាច់ ។ អាស្រ័យហេតុនេះ ការងារសហការណ៍ជាមួយមន្ត្រីរបស់ទីភ្នាក់ងារដែលពាក់ព័ន្ធដូចជា MAFF MRD MOT និង NGOs ដែលកំពុងអនុវត្តកម្មវិធីដែលដូច ឬ ស្រដៀងគ្នានៅក្នុង តំបន់គំរោងនឹងអាចទទួលបានការណែនាំអំពីដំណាក់កាលផែនការ ។

## 12.9 ការត្រួតពិនិត្យ និង ការវាយតំលៃផែនការ

ការត្រួតពិនិត្យ និង ការវាយតំលៃ (M & E) លើផលិតកម្មកសិកម្មនៅក្នុងគំរោងគួរត្រូវធ្វើក្រោយការសាងសង់ប្រព័ន្ធស្រោចស្រពដើម្បីប៉ាន់ស្មានការប៉ះពាល់គំរោង បញ្ហាក់បញ្ហាទាំងឡាយរបស់អ្នកទទួលផលប្រយោជន៍ និង មូលហេតុដើម្បីទុកជាមេរៀនពីគំរោង និង ងាយស្រួលប្រើប្រាស់មេរៀននេះក្នុងផែនការគំរោងបន្ទាប់ទៀត ។

អ្នកផ្តល់ពត៌មានទូទៅ និង ទម្រង់ការសំរាប់ M & E មានបង្ហាញក្នុងទំរង់ 12 ដែលមានកំរិតដូចខាងក្រោម :

- ទំហំផលិតកម្មកសិផល ( ផ្ទៃដីដាំដុះ និង ទិន្នផលមធ្យម)
- ការប្រើប្រាស់សំភារៈពិតប្រាកដ
- បរិមាណលក់ និង តំលៃផលិតផល

- ស្បៀងគ្រប់គ្រាន់
- ការផ្គត់ផ្គង់សំភារៈ
- សកម្មភាពពង្រីក
- សកម្មភាពក្រុមកសិករដែលពាក់ព័ន្ធជាមួយវិស័យកសិកម្ម